THE EDUCATION STATE

# ដំបូន្មានដ៏មានប្រយោជន៍សម្រាប់ការផ្លាស់ប្តូរទៅសាលារៀនធម្មតា

ទៅលេងសាលារៀនថ្មី ដើម្បីប្រាកដថាកូនរបស់អ្នកស្គាល់ចំណាំច្បាស់។ អនុវត្តការធ្វើដំណើរទៅ និងមកពីសាលារៀន។

ប្រសិនបើអ្នកគ្រោងទៅយកកូនរបស់អ្នកក្រោយពេលរៀន ចូរព្រមព្រៀងគ្នាអំពីពេលវេលា និងទីកន្លែង។ សាលារៀនមួយចំនួន ផ្តល់ជូនការថែរក្សាក្មេងក្រោយម៉ោងសាលា ប្រសិនបើអ្នកត្រូវការ។

ចូលរួមការប្រជុំផ្តល់ព័ត៌មាន ហើយលើកទឹកចិត្តកូនរបស់អ្នកឱ្យចូលរួមក្នុងសកម្មភាពណែនាំ។

ចូលរួមការប្រជុំផ្តល់ព័ត៌មាន ហើយលើកទឹកចិត្តកូនរបស់អ្នកឱ្យចូលរួមក្នុងសកម្មភាពណែនាំ។

ទាក់ទងសាលារៀនរបស់កូនអ្នកដើម្បីសេវាបកប្រែភាសាដោយឥតគិតថ្លៃ ប្រសិនបើចាំបាច់។ សេវានេះអាចរកបានសម្រាប់សកម្មភាពជាក់លាក់មួយចំនួន។

ផ្តល់ជូនសាលារៀននូវព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់អ្នកដើម្បីឱ្យបុគ្គលិកអាចទាក់ទងមកអ្នក ប្រសិនបើពួកគេត្រូវការ។ ចូរដឹងពីលេខទូរស័ព្ទរបស់សាលារៀន។

ស្នើសុំកាលវិភាគថ្នាក់រៀន ដើម្បីឱ្យអ្នកបានដឹងពីថ្នាក់រៀនមួយណាដែលកូនរបស់អ្នកមាន។ ប្រាប់សាលារៀន ប្រសិនបើកូន របស់អ្នកនឹងត្រូវអវត្តមាន ឬមករៀនយឺត។

ឱ្យសាលារៀនបានដឹង ប្រសិនបើកូនរបស់អ្នកមានបញ្ហាសុខភាព ឬតម្រូវការពិសេសណាមួយ។ និយាយទៅកាន់សាលារៀន ប្រសិនបើអ្នកមានការព្រួយបារម្ភណាមួយ។

មុនពេលចាប់ផ្តើមចូលរៀន ចូរទិញឯកសណ្ឋានសាលារៀនរបស់កូនអ្នក។សាលារៀនមួយចំនួនក៏នឹងលក់ឯកសណ្ឋានដែលគេប្រើរួចហើយដែរ។

រៀបចំទិញសៀវភៅ និងសម្ភារៈសិក្សាដែលត្រូវការ - សួរសាលារៀនសម្រាប់បញ្ជី និងរបៀបបញ្ជាទិញ។

សរសេរឈ្មោះកូនរបស់អ្នកលើវត្ថុទាំងឡាយ ដូចជាសម្លៀកបំពាក់ និងសម្ភារៈទាំងអស់របស់ពួកគេ។

សាលារៀនអាចតម្រូវឱ្យសិស្សមានឧបករណ៍ដើរយួរនឹងដៃ ឬ iPad។ សួរសាលារៀនអំពីប្រភេទមួយណាដែលកូនរបស់អ្នកនឹងត្រូវការ។

វេចខ្ចប់អាហារដែលមានសុខភាពល្អ។ ស្វែងយល់ឱ្យបានដឹងថាតើសាលារៀនមានកន្លែងលក់ចំណីអាហារ ឬអត់។

លើកទឹកចិត្តឱ្យកូនរបស់អ្នកចូលរួមក្លឹបកិច្ចការគ្រូដាក់ឱ្យធ្វើនៅផ្ទះ ឬសកម្មភាពក្រៅសាលាដទៃទៀត។

ប្រសិនបើត្រូវការជំនួយហិរញ្ញវត្ថុ សូមទាក់ទងសាលារៀនកូនរបស់អ្នកដើម្បីទទួលបានការផ្គត់ផ្គង់ហិរញ្ញវត្ថុដើម្បីបង់ថ្លៃសាលា។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ **www.education.vic.gov.au/parents/going-to-school**

19-0008

VICTORIA State Government | Education and Training